# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ: ០៨ សសរ

## សេចក្តីសម្រេច

### ស្តីពី

### ការតែងតាំងថ្នាក់ដឹកនាំក្រុមប្រតិបត្តិការសន្តិសុខ ថ្នាក់ដឹកនាំក្រុមត្រួតពិនិត្យច្រកទ្វារ និងថ្នាក់ដឹកនាំក្រុមត្រួតពិនិត្យបន្ទប់ទទួលភ្ញៀវពិសេស នៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ

---

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យ ច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៤ ស្តីពីការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសេចក្តីសំរេចលេខ ១៥សសរ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងសមាជិកគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ

Decision to create Phnom Penh Sec Team.doc

- បានឃើញសេចក្តីសំរេចលេខ ៩១សសរ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការកែតម្រូវសមាជិកគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ
- ដោយបានការឯកភាពពីក្រសួង ស្ថាប័នសាមី

## សម្រេច

**ប្រការ ១.-**

ត្រូវបានតែងតាំងជាថ្នាក់ដឹកនាំក្រុមប្រតិបត្តិការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដែលមានសមាសភាពដូចខាងក្រោម :

- លោក **ម៉ឹន នី** នាយកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ប្រធាន
- លោក **ច្រាត់ សុខា** នាយការិយាល័យទី ៣ បញ្ជាការដ្ឋានកងទ័ពជើងអាកាស អនុប្រធាន
- លោក **សួន រិនឌី** នាយរងខុទ្ទកាល័យសាលាក្រុងភ្នំពេញ អនុប្រធាន
- លោក **សុខ ផល** ប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ អគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ អនុប្រធាន
- លោក **ស៊ិន្ន សារ៉ុល** ប្រធាននាយកដ្ឋានសន្តិសុខ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល អនុប្រធានប្រចាំការ
- លោក **សុខ សំអឿន** នាយរងការិយាល័យទីបញ្ជាការដ្ឋានកងទ័ពជើងអាកាស សមាជិក
- លោក **ខៀវ សំអាន** ប្រធានការិយាល័យគយ និងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- លោក **ស៊ុំ ណារុន** អនុប្រធាននាយកដ្ឋានកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម សមាជិក
- លោក **ទាំង ណារ៉ុន** នាយរងការិយាល័យប្រតិបត្តិការទីបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
- តំណាងក្រុមហ៊ុនសេវាកម្មគ្រប់គ្រងចរាចរដែនអាកាសនៃព្រះរាជាណាចក្រកម្ពុជា សមាជិក
- តំណាងក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ សមាជិក

**ប្រការ ២.-**

ត្រូវបានតែងតាំងជាថ្នាក់ដឹកនាំក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដែលមានសមាសភាពដូចតទៅ :

- លោក **ម៉ឹន នី** នាយកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ប្រធាន
- លោ **ពិន ពិសិដ្ឋ** អនុប្រធាននាយកដ្ឋានជនបរទេស អគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ អនុប្រធាន
- លោក **ខៀវ សំអាន** តំណាងទីចាត់ការគយ មន្ត្រីគយ និងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន.
- លោក **ស៊ុំ ណារុន** អនុប្រធាននាយកដ្ឋានកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម សមាជិក
- តំណាងក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ សមាជិក

**ប្រការ ៣.-**

ក្រុមត្រួតពិនិត្យនៅទីស្នាក់ការអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ចែកចេញជាពីរផ្នែកគឺ :

**ផ្នែកទី ១ :**

ក្រុមត្រួតពិនិត្យនៅស្ថានីយ៍អ្នកដំណើរអន្តរជាតិ មានសមាសភាព :

-លោក **ឡូន ខៀម** នាយការិយាល័យច្រកទ្វារព្រំដែន នាយកដ្ឋានជនបរទេស អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ប្រធាន

-លោក **ខៀវ សំអាន** ប្រធានការិយាល័យគយ និងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

-លោក **ស៊ឺ ណារុន** អនុប្រធាននាយកដ្ឋានកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម សមាជិក

-លោក **ឃី យូខេង** មន្ត្រីត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

- លោក **ទំរ យ៉ាង** មន្ត្រីភូតគាមអនាម័យ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

-កម្លាំងសន្តិសុខនៃក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ សមាជិក

**ផ្នែកទី ២ :**

ក្រុមត្រួតពិនិត្យនៅមណ្ឌលឃ្លាំងទំនិញ មានសមាសភាព :

- លោក **ខៀវ សំអាន** ប្រធានការិយាល័យគយ និងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធាន

-លោក **ស៊ឺ ណារុន** អនុប្រធាននាយកដ្ឋានកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម សមាជិក

- លោក **មាស ខេមរា** មន្ត្រីភូតគាមអនាម័យ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

- លោក **ម៉ឹង សុវណ្ណ** មន្ត្រីត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

-លោក **ស្ទួន ម៉ុណ្ណារា** មន្ត្រីភូតគាមអនាម័យ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

-កំលាំងសន្តិសុខ នៃក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ សមាជិក

**ប្រការ ៤.-**

ត្រូវបានតែងតាំងជាថ្នាក់ដឹកនាំសមត្ថកិច្ច នៅបន្ទប់ទទួលភ្ញៀវពិសេស នៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដែលមានសមាសភាពដូចខាងក្រោម :

-លោក **ស្វាយ សារឿន** ប្រធានសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ ភ្នំពេញ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ប្រធាន

-លោក **ឌួង ខឿម** នាយការិយាល័យច្រកទ្វារព្រំដែន នាយកដ្ឋានជនបរទេស នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ អនុប្រធាន

- លោក **ខៀវ សំអាន** ប្រធានការិយាល័យគយ និងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

-លោក **ស៊ុំ ណារុន** អនុប្រធាននាយកដ្ឋានកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម សមាជិក

- កម្លាំងសន្តិសុខក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ សមាជិក

**ប្រការ ៥.-**

ក្រុមប្រតិបត្តិការសន្តិសុខ ក្រុមត្រួតពិនិត្យច្រកទ្វារ ក្រុមត្រួតពិនិត្យមណ្ឌលឃ្លាំងទំនិញ និងកំលាំងមានសមត្ថកិច្ច នៅបន្ទប់ទទួលភ្ញៀវពិសេស នៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ត្រូវអនុវត្តការងារស្របតាមតួនាទី ភារកិច្ច ដូចមានខ្លឹមសារ និងបទប្បញ្ញត្តិ ដែលចែងក្នុងអនុក្រឹត្យ លេខ ០៦ អនក្រ. បក ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៤ ស្តីពីការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៦.-**

អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ប្រការ ២ ប្រការ ៣ និងប្រការ ៤ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ**

**សុខ អាន**

**កន្លែងទទួល**

- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងទេសចរណ៍
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- ឯកសារ-កាលប្បវត្តិ